**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ០៤១.សប្រក

# សេចក្តីប្រកាសច្រានចោល
# ការចំអាន់ និងមូលបង្កាច់របស់ភាគីថៃ
# លើការសម្រេចផ្អាកការធ្វើដំណើរឆ្លងកាត់ព្រំដែនកម្ពុជាជាប់ជាមួយថៃ

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិជ្រាបថា បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា សម្រេចផ្អាកការធ្វើដំណើរចេញ-ចូលទាំងស្រុង នៅតាមច្រកទ្វារព្រំដែនកម្ពុជាជាមួយថៃ ចាប់ពីទីថ្ងៃ១៣ ខែធ្នូ ឆ្នាំ២០២៥ មកនោះ ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលថៃ បន្ទរពីក្រោយដោយអ្នកអត្ថាធិប្បាយ និងប្រព័ន្ធផ្សព្វផ្សាយថៃជ្រុលនិយមគ្មានវិជ្ជាជីវៈមួយចំនួនផង បានធ្វើសេចក្តីថ្លែងការណ៍ រិះគន់បកស្រាយ និងផ្សព្វផ្សាយជាបន្តបន្ទាប់ ដោយចាត់ទុកការសម្រេចរបស់កម្ពុជាថាជាការរំលោភបំពានសិទ្ធិមនុស្ស ផ្ទុយពីច្បាប់ និងអនុសញ្ញាអន្តរជាតិទៅវិញ។

**ក្រសួងមហាផ្ទៃ** សូមបញ្ជាក់ជូនថាក្នុងស្ថានភាពប្រឈមការឈ្លានពានប្រដាប់អាវុធធ្ងន់ធ្ងរ ដោយភាគីថៃ បានប្រើយន្តហោះចម្បាំង F16 គ្រាប់បែកចង្កោម ផ្សែងពុល និងគ្រាប់ផ្លោងចូលជ្រៅក្នុងដែនអធិបតេយ្យកម្ពុជា តាមច្បាប់អន្តរជាតិ រាជរដ្ឋាភិបាលមានកាតព្វកិច្ចចម្បង ការពារអាយុជីវិត និងសុវត្ថិភាពជនស៊ីវិល ទាំងពលរដ្ឋខ្មែរ និងជនបរទេស រួមទាំងថៃ។ ការផ្អាកនេះ ជាវិធានការចាំបាច់ដើម្បីកាត់បន្ថយហានិភ័យនៃការស្លាប់ និងរបួសរបស់ជនស៊ីវិលពីការបាញ់ប្រហារនៅតាមបណ្តោយព្រំដែន រវាងប្រទេសទាំងពីរ។

**អ្នកនាំពាក្យរងក្រសួងមហាផ្ទៃ** ក៏បានចេញបញ្ជាក់បន្ថែមបន្តបន្ទាប់ លើសេចក្តីប្រកាសព័ត៌មាន ស្តីពីការផ្អាកដំណើរការច្រកទ្វារព្រំដែនរវាងកម្ពុជាជាប់ជាមួយថៃ ដែលបាននិងកំពុងមានបញ្ហាប្រឈមជាមួយគ្នាម្តងជាពីរដងរួចហើយ។ តើជាការភាន់ច្រឡំ យល់មិនជ្រៅលើអត្ថន័យ ឬធ្វើមិនយល់ ឬក្នុងចេតនាទុច្ចរិតបង្កើតរឿងលើរឿង? ការលើកឡើងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ អ្នកអត្ថាធិប្បាយ និងប្រព័ន្ធផ្សព្វផ្សាយថៃ ថាកម្ពុជាសម្រេចផ្អាកការធ្វើដំណើរឆ្លងកាត់ព្រំដែន ដើម្បីឃាត់ ឬបង្ខាំងពលរដ្ឋថៃ និងជាការបំបិទសិទ្ធិសេរីភាពនៃការធ្វើដំណើរ ឬបំពានលើច្បាប់ និងអនុសញ្ញាអន្តរជាតិនោះ គឺជាប្រការមិនត្រឹមត្រូវឡើយ។ ផ្ទុយទៅវិញ គឺជាការបង្ហាញភាពកំសោយនៃការងារគ្រប់គ្រងរដ្ឋបាល ឬជាការមិនអើពើចំពោះសកម្មភាពឈ្លានពានដ៏ធ្ងន់ធ្ងររបស់កងទ័ពខ្លួនលើកម្ពុជា ឬហាក់ដូចជាបញ្ជាក់ពីកង្វះខាតការយល់ដឹងខាងច្បាប់ និងអនុសញ្ញាអន្តរជាតិរបស់ភាគីថៃ។

ជាថ្មីម្តងទៀត **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមបញ្ជាក់ជូនថា ការសម្រេចផ្អាកការធ្វើដំណើរឆ្លងកាត់ព្រំដែនកម្ពុជាទាំងគោក និងទឹកជាប់ជាមួយថៃនេះ គឺអនុវត្តតាមបណ្តោយព្រំដែនគោកកម្ពុជា-ថៃតែប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលការធ្វើដំណើរតាមផ្លូវអាកាស ឬតាមច្រកទ្វារព្រំដែនកម្ពុជាជាប់ជាមួយប្រទេសផ្សេង។

ចំពោះផ្លូវអាកាស ក្នុងករណីពលរដ្ឋកម្ពុជា និងពលរដ្ឋថៃមានចំនួនច្រើន ចង់ចាកចេញពីប្រទេស

មួយទៅកាន់ប្រទេសមួយ ពោលគឺ ប្រទេសដើមកំណើតរៀងៗខ្លួនវិញ សូមឱ្យបង្កើនជើងហោះហើរដែលមានស្រាប់។

អាស្រ័យហេតុនេះ សូមសាធារណជនជាតិ និងអន្តរជាតិជ្រាប។

ថ្ងៃ អាទិត្យ ៩រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥

**Press Release**

**Rejecting Misinformation and Distortion by the Thai Side Regarding the Decision to Suspend Cross-Border Travel Between Cambodia and Thailand**

**The Ministry of Interior of the Royal Government of Cambodia** wishes to inform the national and international community that, following the Royal Government of Cambodia's decision to fully suspend entry and exit at Cambodia - Thailand border checkpoints with effect from 13 December 2025, senior leaders and high-ranking officials of the Thai government - supported by certain unprofessional and extremist Thai commentators and media outlets - have repeatedly issued statements, analyses, and publications portraying Cambodia's decision as a violation of human rights and as contrary to international law and conventions.

**The Ministry of Interior** wishes to clarify that, in the context of facing severe armed aggression by the Thai side - including the use of F-16 fighter aircraft, cluster munitions, toxic smoke, and projectiles penetrating deep into Cambodia's sovereign territory - international law obliges the government to give primary protection to the lives and safety of civilians, including Cambodian citizens and foreign nationals, with Thai nationals included. The suspension of cross-border travel is therefore a necessary measure to reduce the risk of civilian deaths and injuries resulting from armed attacks along the border between the two countries.

**The Deputy Spokesperson of the Ministry of Interior** has also repeatedly provided clarifications in connection with press releases concerning the suspension of operations at Cambodia–Thailand border checkpoints, an issue that has already arisen on several occasions. Whether due to misunderstanding, lack of depth in comprehension, deliberate misinterpretation, or malicious intent to fabricate narratives, claims by Thai leaders, senior officials, commentators, and media that Cambodia's decision aims to detain or confine Thai nationals, restrict freedom of movement, or violate international law and conventions are entirely unfounded. On the contrary, such assertions reflect weaknesses in administrative governance, disregard for the Thai military's serious acts of aggression against Cambodia, or a lack of understanding of international law and conventions on the part of the Thai side.

Once again, **the Ministry of Interior of the Royal Government of Cambodia** wishes to clarify that the decision to suspend cross-border travel between Cambodia and Thailand applies only to land border crossings along the Cambodia–Thailand border, and does not include air travel or border crossings between Cambodia and other countries.

Regarding air travel, in the event that large numbers of Cambodian or Thai nationals wish to return to their respective countries of origin, the relevant authorities of each state should increase existing flight services accordingly.